ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ០៥ ខែឧសភា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ពិធីបើកសិក្ខាសាលាស្តីពីកំណែទម្រង់រដ្ឋបាលសារពើពន្ធរបស់ប្រទេសម៉ាឡេស៊ី Tax Administration Reform in Malaysia

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារបានរៀបចំបើកសិក្ខាសាលាស្តីពីកំណែទម្រង់រដ្ឋបាលសារពើពន្ធរបស់ប្រទេសម៉ាឡេស៊ី ក្រោមអធិបតីភាពរបស់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដែលធ្វើបទបង្ហាញដោយ ឯកឧត្តម Tan Sri Dr. Mohd. Shukor Mahfar ដែលជានាយកប្រតិបត្តិ (Chief Executive Officer) Inland Revenue Board of Malaysia និងចូលរួមពីសំណាក់អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោក លោកស្រីប្រធាន-អនុប្រធាននាយកដ្ឋាន លោក លោកស្រី ប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។




ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** បានមានប្រសាសន៍ថា ជំនួសមុខឱ្យថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារទាំងអស់ និងរូបខ្ញុំផ្ទាល់ សូមសំដែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងរំភើបរីករាយឥតឧបមា និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ដំណើរបេសកកម្មដ៏មានតម្លៃរបស់ Tan Sri Dr. Mohd. Shukor Mahfar, នាយកប្រតិបត្តិ (Chief Executive Officer) និង Mr. Mohammed Noor Ahmad, អនុប្រធាននាយកដ្ឋាន (Deputy Director), Tax Operation Department, Inland Revenue Board of Malaysia ដែលបានឆ្លៀតឱកាសដ៏មមាញឹក អញ្ជើញចូលរួមធ្វើបទឧទ្ទេសនាមចែករំលែកចំណេះដឹង និង បទពិសោធន៍ស្តីពីកំណែទម្រង់រដ្ឋបាលសារពើពន្ធនៅប្រទេសម៉ាឡេស៊ី នាឱកាសនេះ ។




ក្នុងឱកាសនេះផងដែរ ឯកឧត្តម **គង់ វិបុល** បានអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ដែលបានជួយឧបត្ថម្ភគាំទ្រក្នុងគម្រោងកិច្ចសហប្រតិបត្តិការនេះ។ វត្តមាន Tan Sri Dr. Mohd. Shukor Mahfar និង Mr. Mohammed Noor Ahmad បានមកធ្វើបទឧទ្ទេសនាមបង្ហាញជូនអស់លោក លោកស្រី នាងកញ្ញា ជាថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារ នៅក្នុងអង្គសិក្ខាសាលាស្តីពី Tax Administration Reform ក្នុងគោលបំណង ចែករំលែកបទពិសោធន៍ ពី IRBM និងកិច្ចពិភាក្សានឹងត្រូវបានជំរុញបង្កើនការយល់ដឹង សម្រាប់សកម្មភាពកំពុងបន្តលើកំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារក្នុងចំណោមមន្ត្រីទាំងឡាយ។

ឯកឧត្តម **គង់ វិបុល** បានផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ ត្រូវយកចិត្តទុកដាក់ខិតខំប្រឹងប្រែងស្តាប់គ្រូឧទ្ទេសនាមឱ្យបានស៊ីជំម្រៅ បំផុសសំណួរ រាល់ចម្ងល់ទាំងឡាយ និងក្រេបយកបទពិសោធន៍ល្អៗ ដើម្បីសិក្សាស្វែងយល់មកអនុវត្តការងារ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

តាងនាមឱ្យថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រជាថ្មីម្តងទៀត ចំពោះ លោក Tan Sri Dr. Mohd. Shukor Mahfar និង Mr. Mohammed Noor Ahmad លោក លោកស្រី ជាតំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន ប្រចាំកម្ពុជា និងលោក លោកស្រី អ្នកជំនាញការប្រចាំ អគ្គនាយកដ្ឋានពន្ធដារ ។

**អគ្គនាយកដ្ឋានពន្ធដារ**